# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាល់-កាស៊ឹម صلوات الله عليه والسلام



សៃយីដ្ធ ម៉ាស្ទូឌី អាយ៉ាទុលឡ៉ហ៊ី

ស្ហាគីប បេនបេឌីរ៉ា

بسم الله الرحمن الرحیم

## អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

-ព្រះនាម ៖ មូសា ។

-ព្រះនាមចំតើត ៖ អាល់-កាស្ហ៊ឹម ។

-ព្រះគារវៈនាម ៖ អាប៊ូ អាល់-ហ្ហាសាន់ ។

-ព្រះនាមព្រះបិតា ៖ យ្ហ៉ាក៍ហ្វារ អាស់ស្ស៊ឌិក្ក ។

-ថ្ងៃប្រសូត ៖ ថ្ងៃទី ៧ ខែស្វ៊ហ្វារ ឆ្នាំប្អី ១២៨ សករាជហ៊្ជីច្ជរ៉េះត្ត៍ ។

-រយៈពេលអ៊ីម៉ាម៉ាស្ទ់ព្រះអង្គ ៖ ៣៤ ឆ្នាំ ។

-ថ្ងៃចូលទិវង្គតឌ្ឋទទួលទុក្ករកម្មឌ្ឋ ៖ ថ្ងៃទី ២៥ រ៉យ្ហ៉ាប់ ឆ្នាំ ១៨៣ សករាជ

ហ៊្ជីច្ជរ៉េះត្ត៍ ។

-កន្លែងបញ្ចុះព្រះរាជសព ៖ អាល់-កាស្ហ៊ឹមីយ៉ាស្ទ់ បាក៍ដ្ឋាដ្ឋ ។



ٱلۡحَمۡدُ لِلَّهِ رَبِّ ٱلۡعَٰلَمِينَ

20/06/2016

# បញ្ជីមាតិកា


កំណើត ............................................................ 6
ពន្លឺសីលធម៌របស់ព្រះអង្គ صلوات الله عليه والسلام ............................................................ 8
ចិត្តសប្បុរសរបស់អ៊ីម៉ាំ صلوات الله عليه والسلام ............................................................ 11
    កញ្ចប់ថវិការបស់អាល់-កាស៊ីម صلوات الله عليه والسلام ............................................................ 13
    បុណ្យរំលឹកអាស្ហ៊ូរ៉អ៍ ............................................................ 16
អ៊ីម៉ាំនិងការប្រកបអាជីព ............................................................ 20
ការកែប្រែ ............................................................ 22
អ៊ីម៉ាំនិងតបៈ (ការកាន់វត្តយ៉ាងតឹងរ៉ឹង) ............................................................ 24
ឯបាក់ដ្ហាដ់ ............................................................ 31
ការកាប់សម្លាប់នៅឯហ្សាក់ ............................................................ 33
សម័យអារ៉ស្ហ៊ីដ ............................................................ 35
    ការកាប់សម្លាប់ជាថ្មី ............................................................ 36
    ប្រមាថចេតិយអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ............................................................ 38
អ៊ីម៉ាំ صلوات الله عليه والسلام តស៊ូដោយសន្តិវិធី ............................................................ 39
    រឿងស្វហ្វ៉ានអ្នកបរអូដ្ឋ ............................................................ 40
    រាជមន្ត្រី អ៊ាលី ប៊ិន យ៉ាក់ទ្វីន ............................................................ 42
កិច្ចសន្ទនាជាមួយបុគ្គលកាន់អំណាចផ្តាច់ការ ............................................................ 43
ក្មួយក្បត់ ............................................................ 46
ការចាប់ខ្លួនអ៊ីម៉ាំ صلوات الله عليه والسلام ............................................................ 49
បដិសេធសន្ធានកម្ម ............................................................ 52
អ៊ីម៉ាំ صلوات الله عليه والسلام ទទួលទុក្ករកម្ម ............................................................ 54
សិស្សរបស់អ៊ីម៉ាំ ............................................................ 55




*ប្លាតុង* (Platon ឬ Plato) *ហៅថា វិចារវិទ្យា គឺវិជ្ជាមួយដែលគេថ្លែងអំពីសាសនាវិទ្យាដោយមិនបាច់ឆ្លងកាត់តាមទ្រឹស្តីទស្សនៈវិជ្ជា (ពោលគឺ និយាយអំពីរឿងសាសនាដោយវិធីឆាយយល់) ។*

## សម្រង់ព្រះវចនៈត្រចះត្រចង់

*-អ្នកមានសទ្ធាប្រៀបបាននឹងជាសជញ្ជីងពីរដែលដាក់ស្មើគ្នា ។ រាល់គ្រាដែលជំនឿរបស់អ្នកនោះកាន់តែមាំឡើង ឧបសគ្គក៏កាន់តែធ្ងន់ឡើងដែរ ។*

*-ភាពជាអ្នកជិតខាងល្អមិនគ្រាន់តែមិនរំខានអ្នកជិតខាងប៉ុណ្ណោះទេ តែជាពិសេសស៊ូអត់ទ្រាំអ្នកជិតខាងពេលអ្នកនោះរំខាន ។*

*-ថ្ងៃជំនុំជម្រះ គេនឹងហៅបណ្តាអ្នកដែលត្រូវបានរង្វាន់ពីអល់ឡោះហ៍* عز وجل *មានតែបណ្តាអ្នកដែលលើកលែងទោសនិងស្រុះស្រួល ដោយមិនចង់បានរង្វាន់ណាក្រៅពីរង្វាន់អល់ឡោះហ៍* عز وجل *នោះទេដែលនឹងងើបឡើង ។*

*-បុគ្គលណាចោលសាសនាដើម្បីផលប្រយោជន៍ជីវិតលោកកិយ ឬអះអាងថាចោលជីវិតលោកិយដើម្បីសាសនា បុគ្គលនោះមិនមែនគ្នាយើងទេ ។*

បុគ្គលមានចំណេះខ្ពស់ ។ លោកត្រូវពួកអាប់បាស់ចាប់ខ្លួន ត្រូវគេធ្វើទារុណកម្មដើម្បីបង្ខំឲ្យប្រាប់ឈ្មោះពួកស៊ីអាស់ដែលលោកស្គាល់ តែលោកបានតស៊ូយ៉ាងក្លាហាន មិនព្រមចុះចាញ់ទេ ហើយបានជាប់ពន្ធនាគារ ១៧ ឆ្នាំ ។

**-អាលី ប៊ិន យ៉ាក់ទីន** ជាសិស្សម្នាក់របស់អ៊ីម៉ាំអាស់ស្វាឌិក صلوات الله عليه والسلام ដែរ ។ សម័យអ៊ីម៉ែយ៉ាស់ លោកត្រូវសមត្ថកិច្ចអ៊ីម៉ែយ៉ាស់ស្វែងរកចាប់ខ្លួនអស់រយៈពេលយ៉ាងយូរ ។ លុះពួកអាប់បាស់បានឡើងកាន់អំណាច លោកបានចូលទៅក្នុងគណបរិវារពួកគេហើយកាន់តំណែងរាជមន្ត្រី ។ លោកសូមលាលែងពីតំណែង តែអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام បានសូមឲ្យលោកជួយអ្នកគាំទ្រអាស់លុល-បៃត៍ عليهم السلام ដោយអាស្រ័យលើតំណែងនេះ ។ លោកបានបំពេញបេសកកម្មនេះបានយ៉ាងល្អ ។

**-ហ៊ីស្សាំ ប៊ិន អាល់-ហាកាំ** ជាសិស្សម្នាក់របស់អ៊ីម៉ាំអាស់ស្វាឌិក صلوات الله عليه والسلام ។ លោកបានបន្សល់ទុកនូវស្នាដៃជាច្រើន ក្នុងច្រើនវិស័យចំណេះវិជ្ជាយល់ដឹងសាសនាអ៊ីស្លាម ជួយឲ្យវិជ្ជាសាស្ត្រថ្មីមួយបានរីកចម្រើនជាខ្លាំង ដែលគេហៅថាវិជ្ជាសាស្ត្រខាងសម្តី (កាឡាម) ដែលជឿនលឿនជាងអ្វីដែលទស្សនៈវិទូ

សម្រង់ព្រះវចនៈត្រចះត្រចង់.....57
អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام .....58

# កំណើត

អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានប្រសូតថ្ងៃអាទិត្យទី ៧ ខែស្ហ័ហ្វារ ឆ្នាំប្ញី ១២៨ សករាជហ៊ិជ្រ៉េះត៍ នៅឯភូមិអាល់-អាប់វ៉ាអ៊ុ (الأبواء) ត្រង់ចន្លោះម៉ាឌីណាស្ហ៍ និងម៉ាក់កាស្ហ៍ កន្លែងបញ្ចុះសពអាមីណាស្ហ៍ ព្រះមាតារបស់ព្រះសាស្ដា صلى الله عليه وآله وسلم ។

អ៊ីមុាំយ៉ាក់ហ្វារ អាស់ស្ហ័ឌិក្ក صلوات الله عليه والسلام ព្រះបិតារបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មានវចនៈអំពីព្រះមាតារបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ដែលជាជនជាតិម៉ាក្រែប អាម៉ាស្ហ៊ីក (الأمازيغية) ព្រះនាម ហាមីដាស្ហ៍ (حميدة) ថា៖ « ហាមីដាស្ហ៍ជានារីបរិសុទ្ធជ្រះស្អាតចាកមន្ទិល ដូចមាសសុទ្ធ ។»

អាប៊ូ បាស្ហៀរ (أبوبصير) សាវកភក្ដីរបស់អ៊ីមុាំអាស់ស្ហ័ឌិក្ក صلوات الله عليه والسلام បានតំណាលថា៖ ខ្ញុំបាននៅជុំជាមួយអាប៊ូ អ៊ាប់ឌុលឡោះហ៍ صلوات الله عليه والسلام កាលយើងបានដើរកាត់តាមភូមិអាល់-អាប់វ៉ាអ៊ុ ។ អ៊ីមុាំបានបបួលយើងទទួលទានបាយ ។ ក្នុងចន្លោះពេលនេះ គេបានមកប្រាប់ថាហាមីដាស្ហ៍ជិតប្រសូតបុត្រហើយ ។ អ៊ីមុាំក៏បានទៅមើល ។ មិនយូរប៉ុន្មានព្រះអង្គបានត្រឡប់មកវិញ ព្រមទាំងសប្បាយព្រះហឫទ័យទៀតផង ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់ដំណឹងយើងថា៖ «អល់ឡោះហ៍ عز وجل បានប្រទានកូនប្រុសឲ្យខ្ញុំខ្លី កូននេះប្រសើរលើសអ្វីៗដែលអល់ឡោះហ៍ عز وجل បានបង្កើតមក ។» លុះអ៊ីមុាំបានត្រឡប់មកកាន់ម៉ាឌីណាស្ហ៍



គេបានតម្កល់សពអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បីថ្ងៃនៅលើស្ពាន ។ ក្នុងអំឡុងពេលបីថ្ងៃនេះ វេជ្ជបណ្ឌិតកាន់សាសនាគ្រិស្ដម្នាក់បានឲ្យដឹងថាអ៊ីមុាំត្រូវគេដាក់ថ្នាំបំពុលមែន ។ នៅទីបំផុត គេបានអនុញ្ញាតឲ្យបញ្ចុះសពអ៊ីមុាំ ។ អ្នកមានភក្ដីភាពចំពោះអ៊ីមុាំមួយជំបានចូលរួមក្នុងពិធីបុណ្យសពព្រះអង្គ ដើម្បីលាព្រះអង្គ ។ ក្រោយមក កន្លែងបញ្ចុះសពអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ត្រូវគេហៅតាមព្រះនាមព្រះអង្គ សព្វថ្ងៃគេហៅកន្លែងនេះថាអាល់-កាស៊ីមីយ៉ាស្ហ៍ ដែលស្ថិតនៅឯបាក់ដាដ៍ ។

## សិស្សរបស់អ៊ីមុាំ

អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មានសិស្សច្រើននាក់ ។ ព្រះអង្គអាចពឹងពាក់លើសិស្សទាំងនេះបានទាំងស្រុង ដើម្បីបង្ហាត់បង្រៀនឲ្យចេះដឹងជំនឿពិតប្រាកដរបស់សាសនាអ៊ីស្លាម និងផ្សព្វផ្សាយច្បាប់សាសនាដែលសំណាក់មូស្លីមត្រូវការជាបន្ទាន់ ។ សិស្សល្បីៗមាន៖

**-អ៊ីបនូ អាប៊ូ អ៊ុំម៉ែរ៍** ជាសិស្សរបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ក្រោយមកជាសិស្សរបស់បុត្រព្រះអង្គ អ៊ីមុាំអារីឌ៍ صلوات الله عليه والسلام ក្រោយមកទៀតជាសិស្សរបស់ចៅព្រះអង្គ អ៊ីមុាំអាល់-យ៉ាវ៉ាដ៍ صلوات الله عليه والسلام ។ លោកជាសិស្សភក្ដីនិងស្មោះត្រង់ ជា

អ្នកគាំទ្រព្រះអង្គមួយចំនួនបានទទួចសួរអំពីរឿងនេះ ព្រះអង្គមានវចនៈថា៖ «ព្រះបិតាខ្ញុំមានវចនៈតមកពីព្រះបុព្វការីខ្ញុំថា អល់ឡោះហ៍ عزّ وجلّ បានប្រាប់ណាប៊ីដាវុដ ﷺ ថា ប្រជានុរាស្ត្រណាមួយរបស់ព្រះអង្គ ﷺ ស្វែងរកពំនាក់អាស្រ័យពីសត្វលោក ព្រះអង្គ عزّ وجلّ នឹងផ្តាច់ពំនាក់អាស្រ័យពីមេឃ នឹងធ្វើឲ្យដីរញ្ជួយក្រោមជើងអ្នកនោះ ។» អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ចង់ទុកជាមេរៀនតស៊ូប្រឆាំងបុគ្គលប្រព្រឹត្តកន្លងករណីយកិច្ចខ្លួន និងបុគ្គលកាន់អំណាចផ្តាច់ការបែបនេះឯង ។ ព្រះអង្គព្រមនៅក្នុងគុកពិបាកអស់ច្រើនឆ្នាំដើម្បីនឹងមិនផ្តល់ពាក្យដោះសាឲ្យមុស្លីមទាំងឡាយឡើយដើម្បីគេចវេះ មិនព្រមទទួលខុសត្រូវប្រឈមនឹងបុគ្គលកាន់អំណាចផ្តាច់ការ ។

## អ៊ីម៉ាំ صلوات الله عليه والسلام ទទួលទុក្ករកម្ម

បន្ទាប់ពីបានជាប់ឃុំឃាំងអស់រយៈពេលច្រើនឆ្នាំ ស្តេចខ៍លិហ្វអារ៉ស៊្ហីដ បានបញ្ជាឲ្យដាក់ថ្នាំបំពុលអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ។

អ៊ីម៉ាំត្រូវគេបំពុលក្នុងឆ្នាំ ១៨៣ សករាជហ៊ិជ្ជរ៉ោះត៍ នៅក្នុងគុក ។ បន្ទាប់ពីនោះគេបាននាំយកព្រះកាយព្រះអង្គទៅដាក់លើស្ពានស៊ីងឌីជ្ជឡាស់ (دجلة) ដើម្បីបង្ហាញមុស្លីមទាំងអស់ឲ្យឃើញថាព្រះអង្គមិនត្រូវគេសម្លាប់ទេ ។



វិញ ព្រះអង្គ صلوات الله عليه والسلام រៀបចំពិធីលៀងជាសាធារណៈ ហើយបានអញ្ជើញជនក្រីក្រក្នុងស្រុកមកចូលរួមដែរ បីថ្ងៃជាប់គ្នា ។

អ៊ីម៉ាំអាស់ស្ហ៊ឌិក្ក صلوات الله عليه والسلام បានប្រកាសប្រាប់ សាវកជំនិតទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ថា ព្រះរាជបុត្ររបស់ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ជាអ៊ីម៉ាំបន្ទាប់ព្រះអង្គ صلوات الله عليه والسلام ។ ការអធិប្បាយបំភ្លឺនេះបានធ្វើឲ្យបណ្តាសាវករបស់អ៊ីម៉ាំអាស់ស្ហ៊ឌិក្ក صلوات الله عليه والسلام ឈប់ជជែកប្រកែកគ្នាអំពីការស្នងតំណែង ជាពិសេសបន្ទាប់ពីអ៊ីសម៉ាអ៊ីល បុត្ររបស់ព្រះអង្គ صلوات الله عليه والسلام បានស្លាប់ ដែលគេបានចាត់ទុកជាអ្នកដឹកនាំសាសនាស្នងព្រះអង្គ صلوات الله عليه والسلام ។

អ៊ីម៉ាំ មូសា ប៊ិន យ៉ាក់ហ្វារ صلوات الله عليه والسلام មានគុណសម្បត្តិសុក្រឹតសព្វគ្រប់ ។ តែព្រះអង្គ صلوات الله عليه والسلام បានរស់នៅក្នុងស្ថានភាពមួយ ដែលរំលេចឡើងឲ្យឃើញច្បាស់នូវគុណសម្បត្តិមួយចំនួនរបស់ព្រះអង្គ صلوات الله عليه والسلام គឺ៖ អំណត់ ខន្តី សុចរិតភាព សេចក្តីអត់ឱន ។ អ្នកមានសទ្ធាបានយកគុណសម្បត្តិទាំងនេះមកដាក់ជាឈ្មោះចំតើតឲ្យអ៊ីម៉ាំរបស់ខ្លួន ។ តែឈ្មោះចំតើតដែលគេស្គាល់ជាងគេប្រហែលជាឈ្មោះចំតើត ដែលឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ជាងគេនូវចរិយាមារយាទរបស់អ៊ីម៉ាំមូសា ប៊ិន យ៉ាក់ហ្វារ صلوات الله عليه والسلام នោះគឺ អាល់-កាស៊ីម

មានន័យត្រង់ថា បុគ្គលទប់កំហឹង ។

អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានរស់នៅជាមួយព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام អស់រយៈពេលម្ភៃឆ្នាំ ។ អត់ពីព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ទៅ ព្រះអង្គ صلوات الله عليه والسلام បានរស់នៅ ៣៤ ឆ្នាំ ។ ព្រះអង្គ صلوات الله عليه والسلام បានរស់នៅក្នុងពន្ធនាគាររបស់ពួកអុាប់បាស់អស់ពាក់កណ្តាល ៣៤ ឆ្នាំ ។

អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មានរូបរាងស្គមបន្តិច មានសម្បុរដាំដែងនិងមានពុកមាត់ក្រាស់ ។ បណ្តាអ្នកដែលបានជួបព្រះអង្គ صلوات الله عليه والسلام បានឲ្យដឹងថាព្រះអង្គមានលក្ខណៈជាព្រះសាស្តា ។

## ពន្លឺសីលធម៌របស់ព្រះអង្គ صلوات الله عليه والسلام

កាលអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام នៅឯម៉ាឌីណាស្ង់ បុរសម្នាក់ស្អប់ព្រះអង្គ صلوات الله عليه والسلام បំផុត ។ បុរសរូបនោះមិនដែលបិទបាំងអរិភាពចំពោះព្រះអង្គ صلوات الله عليه والسلام និងក្រុមគ្រួសារព្រះអង្គ صلوات الله عليه والسلام ឡើយ ។ រាល់គ្រាដែលព្រះអង្គ صلوات الله عليه والسلام ជួបបុរសនោះៗតែងតែជេរប្រទេច ព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធាជ្រះថ្លា អុាលី صلوات الله عليه والسلام ។ សាវកមួយចំនួនរបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានស្នើឲ្យធ្វើទណ្ឌកម្មបុគ្គលសត្រូវរបស់អាស្ង់លុល-បៃត៍ عليهم السلام រូបនេះ ។ តែអ៊ីមុាំបាន





ទោះជាជាប់ច្រវាក់នៅក្នុងគុកក៏ដោយ ។

ចន្លោះពេលនោះ អ្នកគាំទ្រនិងសាវកមួយចំនួនរបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام សូមព្រះអង្គធ្វើអន្តរាគមន៍ សូមឲ្យស្តេចខ៍លិហ្វដោះលែងព្រះអង្គ ។ មួយចំនួនទៀតបានសន្យាអ៊ីម៉ាំថា បើព្រះអង្គសូមទោសស្តេចខ៍លិហ្វពួកគេនឹងជួយអង្វរស្តេចខ៍លិហ្វឲ្យដោះលែងព្រះអង្គ ។ តែអ៊ីម៉ាំមិនមែនបុគ្គលដែលព្រមធ្វើតាមបុគ្គលកាន់អំណាចផ្តាច់ការនោះទេ ។ ព្រះអង្គមិនបានប្រព្រឹត្តអំពើខុសច្បាប់ណាមួយដែលតម្រូវឲ្យសូមទោសនោះទេ ។ ព្រះអង្គបានសរសេរសំបុត្រទៅអារ៉ស្ស៊ីដថា៖ «រាល់ថ្ងៃដែលបានកន្លងផុតទៅ ជាថ្ងៃទុក្ខវេទនាមួយដែលត្រូវដកចេញសម្រាប់ខ្ញុំ ហើយជាថ្ងៃសុភមង្គលមួយដែលត្រូវដកចេញសម្រាប់លោក ។ បន្ទាប់ពីនោះ យើងនឹងឈានទៅរកថ្ងៃមួយដែលមិនមានទីបញ្ចប់ ថ្ងៃនេះមានតែមនុស្សទុយ៌សទេដែលបរាជ័យ ។»

## **បដិសេធសន្ទានកម្ម**

អ៊ីម៉ាំមិនត្រឹមតែមិនព្រមសូមទោសប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបដិសេធការសម្រុះសម្រួលរវាងព្រះអង្គនិងស្តេចខ៍លិហ្វត្រកូលអាប់បាស់ ។ ពេល



ហាមពួកគេប្រព្រឹត្តអំពើណាមួយទៅលើរូបបុរសនេះ ហើយព្រះអង្គ صلوات الله عليه والسلام សួរថាតើបុរសនេះមានរបរអ្វី ។ ពួកគេបានទូលថាគាត់ធ្វើចម្ការនៅក្បែរម៉ាឌីណាស្ហ៊ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានទៅឯចម្ការបុរសនោះ បានដើរកាត់ចម្ការនោះដោយចេតនាដោយមិនខ្វល់អំពីពាក្យជំទាស់តវ៉ារបស់ម្ចាស់ចម្ការទេ ដែលស្រែកថា៖ «កុំដើរជាន់ដំណាំយើងខ្ញុំ លុះត្រាតែព្រះអង្គ صلوات الله عليه والسلام ទៅដល់ក្បែរបុរសនោះ ។ ព្រះអង្គ صلوات الله عليه والسلام គំនាប់បុរសនោះហើយបានអង្គុយក្បែរគាត់ ។ អ៊ីម៉ាំបានចាប់ផ្តើមនិយាយជាមួយបុរសនេះ ដោយឥតច្រឡោតជាលក្ខណៈមិត្តភាព ហាក់ដូចជាពុំមានអ្វីកើតឡើង ។ ព្រះអង្គ صلوات الله عليه والسلام បានសួរគាត់ថា៖

-តើលោកបានបាត់បង់ដំណាំប៉ុណ្ណា ?»

-១០០ ឌីណារ ។

-តើលោកប៉ាន់ស្មានថា ផលដំណាំរបស់លោកក្នុងរដូវនេះមានតម្លៃប៉ុណ្ណា ?

-ខ្ញុំមិនស្គាល់អាថ៌កំបាំងទេ (កុ្រយ់បាស្ហ៊) ។

-ខ្ញុំបានថាតើលោកប៉ាន់ស្មានតម្លៃផលដំណាំលោកប៉ុណ្ណា ?

-២០០ ឌីណារ ។





អល់ឡោះហ៊ូ عز وجل ។ អភិបាលនគរទើសទាល់ណាស់ដោយសារវត្តមានរបស់អ៊ីម៉ាំ ។ អាកប្បកិរិយារបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام នៅក្នុងមន្ទីរឃុំឃាំងបានបញ្ជាក់ប្រាប់អភិបាលនគរបាស្ស់រ៉ោះត្ត៍ ដែលជាបងប្អូនជីដូនមួយរបស់ស្តេចខ៊ុលិហ្វ ថាអ៊ីម៉ាំមិនអាចជាអ្នកទាមទាររាជ្យបល្ល័ង្កនោះទេ ព្រះអង្គមិនប៉ងប្រាថ្នាធ្វើនយោបាយទេ ។ អភិបាលនគរក៏បានផ្ញើសំបុត្រទៅស្តេចខ៊ុលិហ្វដើម្បីសូមអនុញ្ញាតដោះលែងអ្នកទោស ។ មួម៉ោដោយសារសំបុត្ររបស់អភិបាលនគរបាស្ស់រ៉ោះត្ត៍ ហារូនបានសូមឲ្យបញ្ជូនខ្លួនអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام មកឯបាក់ដាដ់ដោយមានអ្នកតាមការពារយ៉ាងក្រៃលែង ។ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ចេញពីមន្ទីរឃុំឃាំងមួយ ទៅចូលមន្ទីរឃុំឃាំងមួយដូចនេះឯង ។ លុះត្រាតែហារូនសម្រេចចិត្តបញ្ជូនព្រះអង្គទៅឲ្យបុគ្គលអមនុស្សធម៌ឈ្មោះ អាល់-ស៊ីនឌី ប៊ិន ស្ហាហ៊ីក ភ្នាក់ងាររបស់ខ្លួនដែលជាឆ្មាំពន្ធនាគារមួយដែលគួរឲ្យខ្លាចរបស់អាណាចក្រពួកអ៊ាប់បាស់ ។ អាល់-ស៊ីនឌី ប៊ិន ស្ហាហ៊ីកជាបុគ្គលគ្មានមេត្តាដែលធ្លាប់បានប្រព្រឹត្តអំពើឃោរឃៅកន្លងមកហើយក្នុងនាមពួកអ៊ាប់បាស់ ។ ពេជ្ឈឃាដរូបនេះជាបុគ្គលដែលអារ៉ស្ហ៊ីដស្វែងរក ដើម្បីកម្ចាត់អ៊ីម៉ាំសម័យកាលដែលខ្លួនមិនអាចអត់ទ្រាំទទួលយកបាន





អ៊ីម៉ាំ صلوات الله عليه والسلام បានឲ្យប្រាក់បុរសនោះ ៣០០ ឌីណារ ហើយបានលាគាត់ ។

ស្អែកឡើង ពេលអ៊ីម៉ាំ صلوات الله عليه والسلام បានទៅឯម៉ាស់ឃ្ជិដ សត្រូវរបស់ព្រះអង្គ صلوات الله عليه والسلام បានទទួលព្រះអង្គយ៉ាងកក់ក្ដៅ ហើយបានទូលព្រះអង្គ صلوات الله عليه والسلام ថា៖ « អល់ឡោះហ៊ូ عز وجل ទ្រង់ញាណច្បាស់នូវកន្លែងទុកព្រះរាជសារព្រះអង្គ عز وجل ។» បណ្ដាសាវករបស់អ៊ីម៉ាំ صلوات الله عليه والسلام ស្រឡាំងកាំង មឹងមាំង ហារមាត់ចង្ក្រុង ។ អ៊ីម៉ាំ صلوات الله عليه والسلام បានតំណាលរឿងរ៉ាវឲ្យពួកគេជ្រាបកាលពីថ្ងៃមុន ហើយបានផ្ដែផ្ដាំឲ្យពួកគេចៀសវាងការប៉ះទង្គិចគ្នាជាមួយមនុស្សទូទៅ ហើយឲ្យពួកគេកាន់តរិយាបថប្រសើរបំផុតជាមួយពួកគេ ។

## ចិត្តសប្បុរសរបស់អ៊ីម៉ាំ صلوات الله عليه والسلام

និយាយអំពីចិត្តសប្បុរសរបស់អវិរុទ្ធបុគ្គល ហាក់ដូចជាបង្ហាញឲ្យឃើញនូវអ្វីដែលច្បាស់ក្រឡែតស្រាប់ហើយ ។ តែការកត់សម្គាល់នេះមិនគ្មានប្រយោជន៍នោះទេ ។ មែន គេមិនអាចស្មានបានទេថាអវិរុទ្ធបុគ្គលខ្វាចភាពក្រខ្សត់ ឬទេរទន់ទៅរកចំណង់អាក្រក់ណាមួយ ឬក៏ស្រឡាញ់ទ្រព្យលោកិយ ។ សេចក្ដីពិតនេះត្រូវបានបកស្រាយនៅក្នុងកថាបួងសួងដ៏ល្បីល្បាញមួយរបស់អ៊ីម៉ាំអាល់-ម៉ាស់ឌី عجل الله فرجك ឌូអាអ៍ អាល់-នុដ្ឋបាស់ (دعاء الندبة)។

ពេលណាគេនិយាយដល់គុណសម្បត្តិខ្ពង់ខ្ពស់ វិសេសវិសាលទាំងនេះដែលជាសញ្ញាសម្គាល់របស់អ៊ីម៉ាំអាស្ហុលុល-បៃត៍ عليهم السلام ទាំងឡាយ ពេលនោះគេគិតខុសថាពួកអាក៉ាប់តែងតែមានអាកប្បកិរិយាដូចនេះ ដែលគេធ្លាប់តែស្គាល់ច្បាស់ថាមានចិត្តទូលំទូលាយនោះ ។

ត្រង់នេះយើងចង់បង្ហាញឲ្យឃើញ ថាចិត្តសប្បុរសរបស់អ៊ីម៉ាំអាស្ហុលុល-បៃត៍ عليهم السلام ទាំងឡាយមិនបង្កប់ នូវគោលបំណងកើបយកផលប្រយោជន៍លោកិយ ឬស្វែងរកនូវកិត្យានុភាពណាមួយនោះទេ នៅក្នុងចំណោមមនុស្សដែលស្រឡាញ់សប្បុរសធម៌ ស្អប់មច្ឆរិយ (សេចក្តីកំណាញ់) ។

មែន ពួកអ្នកធំដុំអាក៉ាប់មិនអាចថ្លែងប្រាប់ជនឯទៀតបានទេនូវទង្វើសប្បុរសធម៌របស់អាស្ហុលុល-បៃត៍ عليهم السلام នោះ ថាអាស្ហុលុល-បៃត៍ عليهم السلام ចែកកេរមរតករបស់ខ្លួនឲ្យគេលុះត្រាតែគ្មានសល់អ្វីនៅក្នុងហិបខ្លួនឡើយ ថាអាស្ហុលុល-បៃត៍ عليهم السلام បានប្រព្រឹត្តទង្វើទាំងនេះ ចំពោះជនក្រីក្រតោកយ៉ាកដែលគ្មាននរណានឹកនាដល់ ដោយលាក់បាំងខ្លួននៅក្នុងស្បៃរាត្រីកាល មិនឲ្យគេស្គាល់មុខទេ ។ មែន អ៊ីម៉ាំអាស្ហុលុល-បៃត៍ عليهم السلام មានចិត្តសប្បុរសដើម្បីតែអល់ឡោះហ្ញ៉ូ عزوجل ប៉ុណ្ណោះ ។ ភាពថ្លៃថ្នូររបស់អ៊ីម៉ាំអាស្ហុលុល-បៃត៍ عليهم السلام ស្ថិត



នៅឯម៉ាឌីណាស្ហ់ ដោយធ្វើពើជាថាព្រះអង្គជាស្តេចខ៏លិហ្វពិតប្រាកដ ។ គេថែមទាំងនាំជំនូនមកឲ្យព្រះអង្គ ហើយបង់ពន្ធឲ្យព្រះអង្គទៀតផង ។»

ហ្វារូនមិនត្រូវការហេតុផលលើសពីនេះទេ ដើម្បីបង្ហើយជាមួយអ៊ីម៉ាំស្របច្បាប់របស់មុស្លីមទាំងអស់ ។ ព្រោះតែធ្លួតចិត្តដោយសារអំណាចពេក បុរសកំណាចមិនបានឲ្យរង្វាន់បុគ្គលក្បត់ ដែលជាក្មួយរបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام នោះ ឲ្យបានស័ក្តិសមទេ ។ អុាលី ប៊ិន អ៊ីសម៉ាអ៊ីលចេញពីវាំងវិញ ដោយបានទទួលរង្វាន់តែបន្តិចបន្តួច ថែមទាំងឈឺខ្លាំងទៀតផង ជាសញ្ញាបញ្ជាក់ថាមានជម្ងឺដល់ស្លាប់ ។ ដូច្នេះអុាលី ប៊ិន អ៊ីសម៉ាអ៊ីលបាត់បង់ទាំងជីវិតលោកិយ ទាំងជីវិតលោកមុខ ។

## ការចាប់ខ្លួនអ៊ីម៉ាំ صلوات الله عليه والسلام

មិនទុកចិត្តគេទេ ហ្វារូនត្រួតត្រាការប្រតិបត្តិការចាប់ខ្លួនអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ដោយផ្ទាល់តែម្តង ។ ហ្វារូនទៅកាន់ម៉ាឌីណាស្ហ់ បញ្ជាឲ្យនាំខ្លួនអ៊ីម៉ាំទៅកាន់បាស្ហ់ក៉េះត៌ទាំងយប់ ដើម្បីចៀសវាងការបះបោរប្រឆាំងរបស់ប្រជារាស្ត្រ ។ នៅក្នុងមន្ទីរឃុំឃាំងនៃនគរបាស្ហ់ក៉េះត៌ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ជួញព្រះហឫទ័យទៅលើការគោរពសក្ការៈ និងការបំពេញនមស្ការបូជា

បុគ្គលរូបនេះចង់កំហឹងដែលមិនអាចរម្ងាប់បានលើព្រះអង្គ ។ ដោយឃើញថាកាលៈទេសៈអាចផ្តល់ឲ្យនូវឱកាសល្អ ដើម្បីខិតចូលទៅរកស្តេចខ៊ូលិហ្វត្រកូលអ៊ាប់បាស់ អ៊ាលី ប៊ិន អ៊ីសម៉ាអ៊ីលបានសម្រេចចិត្តក្បត់ឪពុកមា (ប្អូនឪពុកធំ) ខ្លួន ហើយបានទៅប្រាប់ស្តេចបាក៊់ដ្ដាដ្ដ់នូវហេតុផលដើម្បីចាប់ខ្លួនអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ។ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ស្គាល់គោលបំណងក្មួយព្រះអង្គ ។ ព្រះអង្គព្យាយាមឃាត់ក្មួយកុំឲ្យទៅកាន់បាក៊់ដ្ដាដ្ដ់ ថែមទាំងបានឲ្យប្រាក់មួយចំនួនធំដើម្បីសងបំណុលគេ ដូចដែលក្មួយព្រះអង្គបានថានោះ ។ តែដោយឃើញថាអ៊ាលី ប៊ិន អ៊ីសម៉ាអ៊ីលប្តេជ្ញាចិត្តទៅកាន់បាក៊់ដ្ដាដ្ដ់ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ប្រាប់គាត់ថា៖ «បើអ្នកសម្រេចចិត្តទៅបាក៊់ដ្ដាដ្ដ់ ចូរកុំចូលរួមក្នុងឃាតកម្មមា ។» អ៊ាលី ប៊ិន អ៊ីសម៉ាអ៊ីលញញឹម មិនស្តី ហើយក៏បានចេញដំណើរទៅកាន់បាក៊់ដ្ដាដ្ដ់ ។

ទៅដល់បាក៊់ដ្ដាដ្ដ់ គាត់បានទៅគាល់ហារូន អាររ៉ស៊ីដ សូមចូលខ្លួនស្មោះស្ម័គ្រ ហើយបានទូលស្តេចខ៊ូលិហ្វថា៖ «ខ៊ូលិហ្វពីរតែម្តង មិនអាចទទួលយកបានទេ ។» ហារូនក្រោធ បញ្ជាឲ្យគាត់អធិប្បាយភ្លាម ។ អ៊ាលី ប៊ិន អ៊ីសម៉ាអ៊ីលបានទូលថា៖ «ទូលបង្គំបានមកចោលមូសា ប៊ិន យ៉ាក់ហ្វារ صلوات الله عليه والسلام



នៅត្រង់ចំណុចនេះឯង ហើយនេះគឺសញ្ញាបញ្ជាក់ឲ្យឃើញចិត្តសប្បុរសរបស់អ៊ីម៉ាំអាស្ហ៍លុល-បៃត៍ عليهم السلام ។ យើងសូមលើកយកអាកប្បកិរិយាថ្លៃថ្នូរពីរដែលគេធ្លាប់បានឃើញមាននៅក្នុងខ្លួនអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ដើម្បីយកមកសំអាងក្នុងរឿងនេះ ។ ភស្តុតាងទាំងពីរនេះបញ្ជាក់ឲ្យយើងឃើញនូវភាពបរិសុទ្ធនៃចិត្តសប្បុរសរបស់ព្រះទូតការីរបស់អល់ឡោះហ៍ عز وجل នៅលើផែនដី ។

## កញ្ចប់ថវិការបស់អាល់-កាស៊ីម صلوات الله عليه والسلام

កាលព្រះអង្គ صلوات الله عليه والسلام រស់នៅឯម៉ាឌីណាស្ហ៍ អ៊ីម៉ាំអាល់-កាស៊ីមតែងតែបារម្ភដល់ជនគោកយ៉ាកជាងគេ ។ ព្រះអង្គបានបន្តធ្វើតាមទំនៀមទម្លាប់របស់ព្រះបុព្វការីទាំងឡាយ عليهم السلام របស់ព្រះអង្គ صلوات الله عليه والسلام គឺ៖ ផ្តល់ស្បៀងដល់ជនក្រីក្រក្នុងស្រុក ក្នុងពេលយប់ដោយមិនឲ្យគេស្គាល់មុខ ។ ម្យ៉ាងទៀត អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام បានបង្កើតវិធីជួយមនុស្សថ្មីមួយ ។ អាស្រ័យវិធីនេះមនុស្សអាចដោះស្រាយបញ្ហាដោយខ្លួនឯងបាន ហើយអាចពឹងពាក់លើខ្លួនឯងបានបើមានថវិកាគ្រប់គ្រាន់ដើម្បីប្រកបអាជីវកម្ម ។ អ៊ីម៉ាំបានប្រគល់ថង់ថវិកាឲ្យទៅជនទ័លក្រចំពួកនេះ ដោយមានចំនួនចាំបាច់សម្រាប់បុគ្គលរាល់គ្នាដែល

មានវិបត្តិ ។ រឿងផង់ផវិការបស់អាល់-កាស៊ីម صلوات الله عليه والسلام កាន់តែល្បីឡើងៗ ។ ពួកមុស្លីមមានសេចក្ដីត្រេកអរ ដែលមានអ្នកជិតខាងដូចអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ដែលក្លាយទៅជានិមិត្តរូបនៃសប្បុរសធម៌ ។

រឿងផង់ផវិការបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام និងរឿងដើរចែកស្បៀងក្នុងពេលយប់ដល់ជនទ័លក្រដែលនៅក្នុងគ្រោះថ្នាក់ បានផ្ទុះបញ្ចាំងឲ្យឃើញថាអ៊ីមុាំមានការទទួលខុសត្រូវលើសង្គមកិច្ចយ៉ាងធំមួយ ។ មែន សកម្មភាពនេះបានប្រព្រឹត្តទៅ ខណៈដែលអំណាចរបស់ពួកអុាប់បាស់មិនទាន់បានទៅដល់កំពូលនៅឡើយទេ និងខណៈដែលវិបត្តិសង្គមកាន់តែស៊ីរូងជ្រៅទៅៗ ដោយសារប្រព័ន្ធឯកសិទ្ធិ (ការប្រកាន់វណ្ណៈ) ដែលពួកអុាប់បាស់បានយកមកប្រើវិញ បន្ទាប់ពីពួកអ៊ូម៉ៃយ៉ាស្ដ ។ ភាពមិនត្រឹមត្រូវក្នុងសង្គមកាន់តែធ្វើឲ្យប្រជារាស្ត្រក្រីក្រអត់ទ្រាំលែងបាន ។

ហេតុអ្វីអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មិនទាញយកឱកាសនេះ ជម្រុញប្រជារាស្ត្រក្រីក្រឲ្យបះបោរជាទូទៅដើម្បីកម្ចាត់អយុត្តិធម៌នូ៎ សំណួរនេះឆ្លើយតែការពិតដូរចត់ណាស់ ។ ឧទាហរណ៍ បើអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានធ្វើដូច្នេះ បានទទួលជោគជ័យក្នុងរឿងនេះមែន ចំណែកឯពួកបដិវត្តន៍និងពួក





អង្គ صلى الله عليه وآله وسلم មិនបានបង្កើតអស់លោកទេ ។»

ការដដែកបែបនេះបានត្រឹមតែធ្វើឲ្យហារូនកាន់តែគុំកួន កាន់តែច្រណែនឬស្សាឡើង ។ ពេលអ៊ីម៉ាំចង់ចេញទៅវិញ ហារូនជូនដំណើរអ៊ីម៉ាំដល់មាត់ទ្វារ ដោយសម្តែងឲ្យឃើញនូវសេចក្តីគោរពជាទីបំផុត ។ អាកប្បកិរិយាបែបនេះបណ្តាលឲ្យអាល់-ម៉ាក់មូនស្រឡាំងកាំង ហើយបានសួរឪពុកខ្លួនរកមូលហេតុនៃសេចក្តីគោរពដ៏ខ្ពង់ខ្ពស់នេះ ។ ឪពុកបានថា៖ «កូនអើយ ឪពុកដឹងថាគេជាអ៊ីម៉ាំស្របច្បាប់របស់សហគមន៍នេះ យើងគ្រាន់តែជាអ្នកស្នងរាជ្យបល្ល័ង្កលួចមកពីគេប៉ុណ្ណោះ ។» អាល់-ម៉ាក់មូនបានស្រែកថា៖ «ហេតុអ្វីមិនឲ្យទៅម្ចាស់រាជ្យវិញ ?» ហារូនបានបករបាំងមុខចេញ ហើយថា៖ «កូនអើយ នេះគឺរាជ្យ ! សូមស្បថចំពោះអល់ឡោះហ៍ عز وجل បើឯងហ៊ានទាមទាររាជ្យនេះ អញនឹងកាត់ក្បាលឯង !»

## ក្មួយក្បត់

អាលី ប៊ិន អ៊ីសម៉ាអ៊ីល ចៅរបស់អ៊ីម៉ាំអាស់ស៊ឌិក صلوات الله عليه والسلام ក្មួយរបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام បានលំអៀងចេញពីមាគ៌ារបស់បុព្វការីខ្លួន ។ ទោះជាឪពុកមា (ឬឪពុកធំ) របស់អាលី ប៊ិន អ៊ីសម៉ាអ៊ីលបានធ្វើល្អលើខ្លួនក៏ដោយ ក៏



បះបោរបានទទួលបរាជ័យក្នុងរឿងនេះ ព្រះអង្គបានបង្កើតរដ្ឋត្រឹមត្រូវតាមច្បាប់និងយុត្តិធម៌មែន ដែលព្រះអង្គដឹកនាំដោយព្រះអង្គផ្ទាល់មែននោះ... តើព្រះអង្គនឹងបានប្រព្រឹត្តប្រសើរជាងព្រះបុព្វការីរបស់ព្រះអង្គទេ គឺព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់មុស្លីមទាំងឡាយ ? ចូរចងចាំឡើងវិញនូវសោកនាដកម្មរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام តើព្រះអង្គ صلوات الله عليه والسلام បានឆ្លងកាត់ការដឹកនាំអំណាចបួនឆ្នាំនោះដូចម្តេចខ្លះ ?

អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام បានជ្រើសយកប្រព្រឹត្តកម្មសង្គមកិច្ច ជាជាងប្រព្រឹត្តកម្មអយុត្តិធម៌ដែលពួកអាប់បាស់បានដាក់ជាផ្លូវការ ។ អាកប្បកិរិយានេះបង្ហាញឲ្យឃើញថាព្រះអង្គ صلوات الله عليه والسلام មិនអើពើចំពោះអំណាច និងសម្បត្តិលោកិយទេ ។ ទោះជាសំណាក់មុស្លីមមិនស័ក្តិសមមានអ្នកដឹកនាំដូចព្រះអង្គទេក៏ដោយ មិនគ្រាន់បើជាងដូនតារបស់ខ្លួនទេក៏ដោយដែលមិនស័ក្តិសមមានអ្នកដឹកនាំនយោបាយដូចអ៊ីម៉ាំទាំងឡាយ عليهم السلام ក្នុងសម័យពួកគេនោះ ក៏ព្រះអង្គ صلوات الله عليه والسلام នៅតែមានព្រះហឫទ័យទូលំទូលាយឥតព្រំដែន មិនអាចចៀសវាងស្រឡាញ់សហគមន៍របស់ព្រះអង្គ صلوات الله عليه والسلام បានទេ មិនអាចចៀសវាងគាំទ្រសហគមន៍នោះបានទេ ។

ដើម្បីជាសម្តេចព្រះមហាឧបកជរបស់អល់ឡោះហ្វ់ عزّ وجلّ នៅលើផែនដី ត្រូវមានកិរិយាមារយាទ ដែលអាចតំណាងព្រះគុណសម្បត្តិរបស់អល់ឡោះហ្វ់ عزّ وجلّ បានគឺ៖ មានហឫទ័យទូលុំទូលាយឥតព្រំដែន មានមហាស្រ័យភាព មានហឫទ័យសប្បុរសឥតលក្ខខណ្ឌចំពោះសព្វសត្វលោក ព្រមទាំងចំពោះសត្វលោកដែលមិនត្រឹមត្រូវផងដែរ ។ នៅក្នុងឌុអាអ៍ អាល់-នុដ្ដបាស្ហ៍ (دعاء الندبة) អ៊ីមុាំអាល់-ស្ហាម៉ាន់ عجل الله فرجك (អ៊ីមុាំរបស់សម័យកាលយើង) បានរំលឹកការពិតមួយនេះគឺ៖ អ៊ីមុាំអាស្ហ៍លុល-បៃត៍ عليهم السلام ជាអវិរុទ្ធបុគ្គលព្រោះតែព្រមទទួលលក្ខខណ្ឌដែលអល់ឡោះហ្វ់ عزّ وجلّ បានដាក់មក ពោលគឺ មិនអើពើចំពោះជីវិតលោកិយសោះឡើយ ប្រព្រឹត្តដើម្បីលោកមុខទាំងស្រុង ។

## បុណ្យរំលឹកអាស៊ូរ៉អ៍

យើងបានដឹងហើយថា ប្រជារាស្ត្រតំបន់ឃូរ៉សាន (خراسان) មានសកម្មភាពខ្លាំងក្លាជាងគេក្នុងការធ្វើបដិវត្តន៍របស់ពួកអាប់បាស់កម្ចាត់ពួកអ៊ូម៉ៃយ៉ាស្ហ៍ ។

ស្តេចខ៉ូលិហ្វអាល់-ម៉ាន់ស៊្វូរ ចង់សម្តែងសេចក្តីគោរពចំពោះទំនៀមទម្លាប់របស់ពួកពែរស៍ ។ ដើម្បីផ្គាប់ចិត្តប្រជារាស្ត្រនេះ ដែលជាអ្នកគាំទ្រអំណាចខ្លួនច្រើនជាងគេ អាល់-ម៉ាន់ស៊្វូរបានចាត់ឲ្យមានពិធីបុណ្យនូរុស្ហ៍ ។ ដើម្បីកុំឲ្យ



ថ្វីបើយើងជាសាលោហិតរបស់អាល់-អាប់បាស់ ឪពុកមារបស់ព្រះសាស្តា صلى الله عليه وآله وسلم ចំណែកឯលោកវិញជាសាលោហិតរបស់អាប៊ូ ត្ហ៍លិប رضي الله عنه ឪពុកមារបស់ព្រះសាស្តា صلى الله عليه وآله وسلم ?» អ៊ីមុាំបានតបថា៖ «យើងជិតព្រះសាស្តា صلى الله عليه وآله وسلم ជាងគេព្រោះអាប់ឌុលឡោះហ្វ់ رضي الله عنه ព្រះបិតារបស់ព្រះសាស្តា صلى الله عليه وآله وسلم ជាបងរបស់អាប៊ូ ត្ហ៍លិប ខាងឪពុកនិងខាងម្តាយ ។ ចំណែកឯអាល់-អាប់បាស់គ្រាន់តែជាប្អូនខាងឪពុកប៉ុណ្ណោះ ។» ហ្វារូនបានសួរមួយសំណួរទៀតថា៖ «ហេតុអ្វីគេហៅលោកថាបុត្រ៉ស៊ូលុលឡោះហ្វ់ صلى الله عليه وآله وسلم ថ្វីបើព្រះអង្គ صلى الله عليه وآله وسلم ជាព្រះអយ្យកោរបស់លោក ចំណែកឪពុករបស់លោកគឺអាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត្ហ៍លិប رضي الله عنه ?» អ៊ីមុាំមានវចនៈថា៖ «ប្រសិនបើព្រះសាស្តា صلوات الله عليه والسلام រស់ឡើងវិញពេលនេះ តើលោកអាចអភិសេកព្រះអង្គ صلى الله عليه وآله وسلم ជាមួយកូនស្រីលោកបានទេ ?» ស្តេចខ៉ូលិហ្វបានឆ្លើយភ្លាមថា៖ «បាន ខ្ញុំនឹងអួតកិត្តិយសនេះដាក់ពួកអារ៉ាប់និងពួកមិនមែនអារ៉ាប់ទាំងអស់ ។» អ៊ីមុាំមានវចនៈថា៖ «ចំណែកឯយើងវិញ ព្រះសាស្តា صلى الله عليه وآله وسلم មិនសូមកូនស្រីយើងអភិសេកជាមួយទេ ហើយយើងមិនអាចអភិសេកព្រះអង្គ صلى الله عليه وآله وسلم បានទេ ។» សម្តីអ៊ីមុាំបានធ្វើឲ្យហ្វារូនភ្ញាក់ផ្អើល ហើយបានសួរថា៖ «ហេតុអ្វី ?» អ៊ីមុាំបានតបថា៖ «ពីព្រោះព្រះអង្គ صلى الله عليه وآله وسلم បានបង្កើតយើង ព្រះ





សំណាក់អាក៉ាប់អាក់អន់ស្រពន់ចិត្ត អាល់-ម៉ានស៊្ទូរ បុរសសម្បូរល្បិច រិះរកមធ្យោបាយស្របច្បាប់មួយដើម្បីបិទបាំងអំពើនេះ ។ សម្រាប់អាល់-ម៉ាន់ស៊្ទូរ មានតែអ៊ីមុាំអាល់-កាស៊្ទឹម صلوات الله عليه والسلام ទេដែលបំពេញកិច្ចការនេះបាន ។ ខ៊ុំលិហ្វបានស្នើសូមឲ្យអ៊ីមុាំទទួលពួកអ្នកមានមុខមាត់និងភ្ញៀវទាំងឡាយ ហើយសូមឲ្យព្រះអង្គទទួលយកនូវអំណោយរបស់ពួកគេក្នុងនាមខ្លួន ។ អ៊ីមុាំបានបដិសេធដាច់អហង្ការ ព្រមទាំងបានរំលឹកប្រាប់ខ៊ុំលិហ្វថាពិធីបុណ្យនេះមិនមានអ្វីទាក់ទងនឹងអ៊ីស្លាមទេ វាគ្រាន់តែជាទំនៀមរបស់ពួកពែរស់ទេ មិនត្រូវចាក់ទុកជាសំខាន់ទេ ។ តែខ៊ុំលិហ្វនៅតែទទូច ការស្នើសូមក្លាយទៅជាបញ្ជាដែលអ៊ីមុាំត្រូវតែអនុវត្តតាមជាចាំបាច់ ។ ដោយឃើញថាចាំបាច់ត្រូវតែធ្វើតាមបញ្ជារបស់ខ៊ុំលិហ្វ អ្នកទទួលខុសត្រូវក្នុងរឿងនេះគឺបុគ្គលឃោរឃៅតែម្នាក់នេះគត់ អ៊ីមុាំក៏បានអង្គុយចាំទទួលភ្ញៀវក្រោមការសង្កេតមើលនៃភ្នាក់ងារម្នាក់របស់ខ៊ុំលិហ្វ ។ ភ្ញៀវរបស់ខ៊ុំលិហ្វនិងភ្ញៀវសំខាន់ៗទាំងឡាយនៃតំបន់ចំណុះខ៊ុំលិហ្វបានចូលមកជួបអ៊ីមុាំអាល់-កាស៊្ទឹម صلوات الله عليه والسلام ម្ដងមួយៗ បានជូនអំណោយតាមទំនៀមទម្លាប់ពែរស់ ។ អំណោយទាំងនោះច្រើនតែមានតម្លៃនិងមានចំនួនច្រើនណាស់ ។ តែអ៊ីមុាំអាល់-កាស៊្ទឹម صلوات الله عليه والسلام មិនយកចិត្តទុកដាក់





ហារូន មានប្រាជ្ញាវាងវៃ និងប្រយ័តខ្លួនប៉ុណ្ណាក៏ដោយ ក៏ហារូននៅតែសង្ស័យអំពីសេចក្តីស្មោះត្រង់លើរូបលោកដែរ ។ បុរសកំណាចរូបនេះបានបញ្ជាឲ្យភ្នាក់ងារម្នាក់របស់ខ្លួនឃ្លាំមើលលោកយកទឹកវូឌុអ៍ តើលោកធ្វើតាមរបៀបស៊ីអ៊ាស្ទ្រឬទេ ។ តែការឃ្លាំមើលនិងការត្រួតពិនិត្យឥតប្រយោជន៍ទេ ហារូនត្រូវការប្រាជ្ញាវាងវៃរបស់ប៊ិន យ៉ាក់ទ្ទីនណាស់ មិនអាចកម្ចាត់លោកចោលជាការប្រុងប្រយ័ត្នជាមុនបាននោះទេ ។ ដូច្នេះ ក្រោមបញ្ជារបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام អ៊ាលី ប៊ិន យ៉ាក់ទ្ទីនបានជួយអ្នកគាំទ្រអាស់ហុល-បៃត៍ عليهم السلام យ៉ាងច្រើន ហើយបានរក្សាកេរ្តិ៍រតេកអ៊ីស្លាមមួយចំនួនធំ ។

## កិច្ចសន្ទនាជាមួយបុគ្គលកាន់អំណាផ្តាច់ការ

កាលដែលបានមកធ្វើទស្សនៈកិច្ចឯនគរម៉ាឌីណាស្ហ ស្តេចខ៊ិលិហ្វហារូនបានកោះហៅអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام មកជួប ។ លុះអ៊ីម៉ាំចូលមកក្នុងដំណាក់របស់ស្តេចខ៊ិលិហ្វៗបានងើបឡើង ធ្វើជាគោរពព្រះអង្គជាទីបំផុត ហើយឲ្យព្រះអង្គគង់ក្បែរខ្លួន ។ ស្តេចខ៊ិលិហ្វគិតថាអាចបង្កអំពល់ទុក្ខដល់អ៊ីម៉ាំអាល់-កាស៊ីមបាននៅចំពោះមុខកូនខ្លួនឈ្មោះអាល់-ម៉ាក់មូន ដោយសារសំណួររៀបចំទុកជាមុន បានទូលអ៊ីម៉ាំថាៈ «ហេតុអ្វីគេស្រឡាញ់លោកជាងយើង

صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់គាត់ថា៖ «លោកល្អសព្វគ្រប់ ទាស់តែលោកជួលអូដ្ឋលោកឲ្យហ្វារូន ។» ស្វហ្វ៉ានបានទូលដោះសារថា៖ «ទូលបង្គំជួលអូដ្ឋឲ្យគេតែពេលណាគេទៅបំពេញពិធីហាជ្ជទេ ។» អ៊ីមុាំមានវចនៈថា៖ «លោកចង់ឲ្យគេត្រឡប់មកពីបំពេញពិធីហាជ្ជវិញ ដោយសុវត្ថិភាពមែនទេ ដើម្បីគេនឹងបង់ប្រាក់ឲ្យលោក?» គាត់បានទូលថា៖ «មែន ។» អ៊ីមុាំមានវចនៈថា៖ «អ្នកណាចង់ឲ្យបុគ្គលដែលប្រព្រឹត្តកន្លងករណីយកិច្ចខ្លួននោះមានជីវិតយឺនយូរ អ្នកនោះជាគនរបស់បុគ្គលនោះ ។» ស្វហ្វ៉ានក៏បានសម្រេចចិត្តលក់អូដ្ឋគាត់ទាំងអស់ចោល ដើម្បីនឹងកុំឲ្យមានទំនាក់ទំនងអ្វីជាមួយបុគ្គលកំណាចត្រកូលអុាប់បាស់តទៅទៀត ។

## រាជមន្ត្រី អុាលី ប៊ិន យ៉ាក់ទ្ទីន

ក្នុងចំណោមអ្នកស្មោះត្រង់ដ៏កម្រទាំងឡាយរបស់អ៊ីមុាំ ដែលព្រះអង្គបានអនុញ្ញាត ឲ្យចូលទៅក្នុងសំណាក់បរិវាររបស់បុគ្គលកំណាចត្រកូលអុាប់បាស់ អុាលី ប៊ិន យ៉ាក់ទ្ទីន ជាអ្នកស្មោះត្រង់ចំពោះអ៊ីមុាំល្បីជាងគេ ដែលប្រកបដោយគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើមុស្លីមទាំងឡាយដោយមិនឲ្យស្តេចខ៊ុលិហ្វត្រកូលអុាប់បាស់ដឹងខ្លួន ។ តែទោះជា ប៊ិន យ៉ាក់ទ្ទីន រាជមន្ត្រីរបស់



ទេ ទុកឲ្យភ្នាក់ងាររបស់ខ៊ុលិហ្វមើលថែទាំម្នាក់ឯង ។ ភ្ញៀវម្នាក់ក្រោយគេ បុរសចំណាស់ បានដើរចូលមករកអ៊ីមុាំ ។ បន្ទាប់ពីបានសម្តែងការអបអរសាទរចំពោះអ៊ីមុាំ គាត់បានសូមអភ័យទោសដែលមិនមានអំណោយផ្ញើព្រះអង្គ ហើយគាត់បានសូមឲ្យអ៊ីមុាំស្តាប់កំណាព្យពីរបីឃ្លាដែលជីតារបស់គាត់បានតែងឡើងស្តីអំពីទុក្ករៈកម្មរបស់អ៊ីមុាំអាល់-ហ៊ូសែន صلوات الله عليه والسلام ។ អ៊ីមុាំរង់ចាំតែឱកាសនេះទេដើម្បីធ្វើឲ្យពិធីបុណ្យនេះ ដែលមិនមែនជាបុណ្យអ៊ីស្លាមទេនោះ ក្លាយទៅជាឱកាសមួយសម្រាប់រំលឹកឡើងវិញនូវសោកនាដកម្មអាស៊ូរ៉អ៊ុំនិងទុក្ករៈកម្មរបស់អ៊ីមុាំអាល់-ហ៊ូសែន صلوات الله عليه والسلام ។ បុរសចំណាស់បានសូត្រកំណាព្យពីរបីឃ្លា ថ្លែងអំពីមនោសញ្ចេតនារបស់បុគ្គលមានសទ្ធាស្មោះត្រង់ម្នាក់ដែលឈឺចិត្ត ព្រោះតែផ្លែដាវនិងគ្រាប់ព្រួញហ៊ានប៉ះពាល់ព្រះកាយព្រះអគ្គមហាប្រមុខរបស់ទុក្ករៈបុគ្គលទាំងឡាយ ។ ការសូត្រកំណាព្យនេះបានធ្វើឲ្យមនុស្សទាំងអស់គ្នារំភើបអនេក ។ អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានទៅជួបភ្នាក់ងាររបស់ខ៊ុលិហ្វ ហើយបានសូមឲ្យទៅសូមបញ្ជាពីម្ចាស់របស់គាត់ថានឹងត្រូវយកអំណោយទាំងនេះទៅទុកឯណា ដែលនៅពាសពេញកន្លែង ។ មិនយូរប៉ុន្មាន ភ្នាក់ងារត្រឡប់មកវិញ ប្រាប់ថាខ៊ុលិហ្វសូមប្រគល់អំណោយ

ទាំងនេះឲ្យទៅអ៊ីមុាំ ។ អ៊ីមុាំបានបែរទៅរកបុរសចំណាស់ បានប្រគល់របស់អស់ទាំងនេះឲ្យទៅគាត់ ធ្វើឲ្យមនុស្សទាំងឡាយភ្ញាក់ផ្អើលអនេក ហើយយល់អំពីសោកនាដកម្មការបាឡាអ៊ុំនិងតម្លៃរបស់វា ។

ទង្វើមួយនេះមិនត្រឹមតែជាទង្វើសប្បុរសធម៌ប៉ុណ្ណោះទេ ថែមទាំងជាការសម្តែងឲ្យឃើញនូវការថ្កោលទោសទាំងស្រុង ចំពោះអំណាចរបស់ពួកអាប់បាស់ ហើយជាការបញ្ជាក់ថាអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ស្មោះត្រង់ចំពោះមាគ៌ាព្រះបុព្វការីទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ជាពិសេសចំពោះព្រះអគ្គមហាប្រមុខរបស់ទុក្ករៈបុគ្គលទាំងឡាយ អ៊ីមុាំអាល់-ហ៊ូសែន صلوات الله عليه والسلام ។ ពិតណាស់ កំណាព្យបីឃ្លាស្តីអំពីអ៊ីមុាំអាល់-ហ៊ូសែន صلوات الله عليه والسلام មានតម្លៃសម្រាប់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ជាងរបស់ទាំងអស់ ដែលគ្រឿងរបស់ខលិហ្វបានយកមកនោះ ។ ទង្វើនេះមានន័យច្បាស់ណាស់ ធ្វើឲ្យខលិហ្វលែងទុកចិត្ត ។ គេអាចសន្និដ្ឋានបានថាខលិហ្វបានស្តាយក្រោយ ដែលបានសូមឲ្យអ៊ីមុាំទទួលអំណោយពីគ្រឿងរបស់ខ្លួនក្នុងឱកាសបែបនេះ ។

## អ៊ីមុាំនិងការប្រកបអាជីព

អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام រស់នៅ អាស្រ័យលើការប្រកបអាជីពចិញ្ចឹម





ស្មោះត្រង់ចំពោះព្រះអង្គ صلوات الله عليه والسلام ថា ស្តេចខ៏លិហ្វអាប់បាស់មិនមែនជាបុគ្គលស្របច្បាប់ទេ ហើយត្រូវចៀសវាងចរចាជាមួយបុគ្គលនេះ ។ ម្យ៉ាងទៀតដើម្បីដោះស្រាយបញ្ហា និងជួយសម្រួលកិច្ចការនានារបស់សំណាក់មុស្លីម ព្រះអង្គបានអនុញ្ញាតឲ្យអ្នកស្មោះត្រង់ចំពោះព្រះអង្គមួយចំនួន ចូលទៅក្បែរស្តេចខ៏លិហ្វ ឲ្យសាកល្បងចូលកាន់មុខងារខ្លះដែលមានប្រយោជន៍ ។

យើងសូមលើកយកនូវព្រឹត្តិការណ៍ខ្លះ ដកស្រង់ពីប្រភពប្រវត្តិសាស្ត្រ ដើម្បីជាបង្អែក ពាក់ព័ន្ធនឹងការតស៊ូដោយសន្តិវិធីរបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ។

## រឿងស្វហ្វ៉ានអ្នកបរអូដ្ឋ

អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ហាមសហប្រតិបត្តិការ ដាច់ខាតជាមួយអាជ្ញាអាប់បាស់ ហើយព្រះអង្គបកស្រាយទង្វើនេះថាជាការព្រមទទួលស្គាល់អំពើសង្កត់សង្កិននិងជាការគាំទ្របុគ្គលទុច្ចរិត ។ អ្នកបរអូដ្ឋល្បីជាងគេសម័យនោះឈ្មោះស្វហ្វ៉ាន ហើយជាអ្នកគាំទ្រអាស់ហ្លុល-បៃត៍ عليهم السلام ។ រាល់ពេលដែលហារូន អាររ៉ស្ហ៊ីដទៅបំពេញពិធីហាជ្ជ គេជាវសេវាកម្មរបស់ស្វហ្វ៉ាន ដើម្បីដឹកជញ្ជូនបរិវារ ។ ថ្ងៃមួយស្វហ្វ៉ានបានទៅលេងអ៊ីម៉ាំអាល់-កាស៊ីម





ជីវិត ។ ព្រះអង្គ صلوات الله عليه والسلام ធ្វើកសិកម្មលើផ្ទៃដីមួយដោយព្រះហស្ដព្រះអង្គ صلوات الله عليه والسلام ឯង ។ ថ្ងៃមួយ ព្រះអង្គ صلوات الله عليه والسلام កំពុងតែធ្វើចម្ការ សាវកម្នាក់របស់ព្រះអង្គបានដើរកាត់តាមនោះ ។ ភ្ញាក់ផ្អើលដែលបានឃើញអ៊ីម៉ាំធ្វើការដោយដៃឯង គាត់បានទូលព្រះអង្គថា៖ «សូមឲ្យទូលបង្គំបានធ្វើពលីកម្មដើម្បីព្រះអង្គ ឯណាកម្មករនៅ មិនមានអ្នកណាធ្វើការឲ្យព្រះអង្គទេ ?» អ៊ីម៉ាំបានឆ្លៀតយកឱកាសនេះរំលឹកបុរសរូបនេះនិងមូស្លីមទាំងឡាយឡើងវិញ នូវបាវចនៈរួមរបស់ព្រះបុព្វបុរសទាំងអស់របស់ព្រះអង្គគឺ៖ ចិញ្ចឹមជីវិតដោយកម្លាំងដៃឯង ។ ហើយព្រះអង្គបានប្រាប់បុរសនោះថា៖ «បុគ្គលទាំងឡាយដែលប្រសើរជាងខ្ញុំនិងព្រះបិតាខ្ញុំបានចិញ្ចឹមជីវិតដោយដៃឯងដែរ ។» បុរសរូបនោះភ្ញាក់ព្រើតបានទូលថា៖ «ពួកគេជាអ្នកណា ?» អ៊ីម៉ាំបានតបថា៖ «ព្រះសាស្ដា صلى الله عليه وآله وسلم របស់អល់ឡោះហ៍ عز وجل ព្រះអង្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាទាំងឡាយ ដូនតាទាំងអស់របស់ខ្ញុំតែងតែប្រកបកិច្ចការដោយដៃឯង ។ នេះជាទម្លាប់របស់ព្រះសាស្ដា عليهم السلام ទាំងឡាយ របស់ព្រះសាស្ដាប្រេសិត عليهم السلام ទាំងឡាយ របស់បណ្ដាអ្នកស្នងព្រះអង្គ عليهم السلام និងរបស់សន្ដបុគ្គលទាំងឡាយ ។»

## ការកែប្រែ



សាស្ដា صلى الله عليه وآله وسلم ក៏ដោយ ។ ដូច្នេះ បុគ្គលរូបនេះបានបញ្ជាឲ្យពន្លិចទឹកចេតិយអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ហាមទៅទស្សនៈការបាឡាអ៍ ធ្វើទណ្ឌកម្មអ្នកណាដែលហ៊ានល្មើសបញ្ជាខ្លួន ។

ទទន្ទឹមនឹងនយោបាយសង្កត់សង្កិនអ្នកគាំទ្រអ៊ាលី និងអ្នកប្រឆាំងនយោបាយជាទូទៅ អាបាស៊ីដព្យាយាមបង្ហាញឲ្យឃើញថាខ្លួនចូលចិត្តផ្សាយសាសនាអ៊ីស្លាមនិងពិធីនានារបស់អ៊ីស្លាម ។ មែន បុគ្គលសាហាវយង់ឃ្នងរូបនេះតែងតែទៅបំពេញពិធីហាជ្ជពីរឆ្នាំម្ដង ។ រៀងរាល់ឆ្នាំចន្លោះនោះ អាបាស៊ីដដឹកនាំដោយខ្លួនឯង ចម្បាំងទល់នឹងអាណាចក្រឯទៀតដែលជាប់ព្រំដែនអាណាចក្រខ្លួន ។

ដូច្នេះ សំណាក់មូស្លីមត្រូវគេណែនាំយ៉ាងសកម្មឲ្យយល់ខុសអំពីលក្ខណៈបុគ្គលរបស់ព្រះចៅកាន់អំណាចផ្ដាច់ការរូបនេះ ។ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ជ្រាបច្បាស់រឿងនេះ ព្រះអង្គរើសយកការតស៊ូដោយសន្ដិវិធីទល់នឹងបុរសកំណាចនៃនគរបាក់ដាដ់ ។

## អ៊ីម៉ាំ صلوات الله عليه والسلام តស៊ូដោយសន្តិវិធី

អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام បានពន្យល់បណ្ដាអ្នកគាំទ្រព្រះអង្គ صلوات الله عليه والسلام និងអ្នក

អារ៉ស្ហ៊ីដ្ឋសួរដដែលជាលើកទីបី ។ ក្អោះហ្ទ៉ុត្ត៍បាស្ទយល់គោលដៅរបស់ព្រះថៅរបស់ខ្លួន បានតបថា៖ «ទូលបង្គំសូមលះបង់សាសនារបស់ទូលបង្គំដើម្បីព្រះអង្គ ។» ខណៈនោះ អារ៉ស្ហ៊ីដ្ឋចង្អុលម៉ាស់រូរ បាវស្មោះត្រង់របស់ខ្លួន ដែលបានឆ្លងកាត់ការល្បងពិសោធន៍រួចហើយ ដោយបានប្រព្រឹត្តការកាប់សម្លាប់យ៉ាងសាហាវយង់ឃ្នង ហើយបានថា៖ «ទៅជាមួយម៉ាស់រូរ ហើយធ្វើតាមបញ្ជាគេ ។»

មកដល់មន្ទីរឃុំឃាំង ម៉ាស់រូរបានប្រាប់ក្អោះហ្ទ៉ុត្ត៍បាស្ទថា៖ «ព្រះថៅខ្លិហ្វបញ្ជាឲ្យលោកសម្លាប់មនុស្សទាំងអស់ដែលនៅក្នុងគុកនេះ ហើយចោលសពពួកគេក្នុងអណ្ដូងទឹក ។» អ្នកទោសទាំងអស់សុទ្ធតែជាកូនចៅរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام និងហ្វាទិម៉ាស្ទ អាស្ហារ៉ែអ៊ុ سلام الله عليها មានចំនួន ៦០ នាក់ មានកូនក្មេងនិងមនុស្សចាស់ ។ ហ្វាមីដ្ឋ ប៊ិន ក្អោះហ្ទ៉ុត្ត៍បាស្ទបានអនុវត្តតាមបញ្ជាព្រះថៅរបស់ខ្លួនឥតរួញរា បានកាត់កអ្នកទោសម្នាក់ៗ ។

## ប្រមាថចេតិយអ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام

ហារូន អារ៉ស្ហ៊ីដ្ឋមិនអធ្យាស្រ័យឲ្យសំណាក់មុស្លីមស្រឡាញ់អ្នកណាក្រៅពីខ្លួនទេ ទោះបីអ្នកនោះគឺអ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ព្រះនត្តា صلوات الله عليه والسلام របស់ព្រះ



អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام មានបំណងចង្អុលទិសឲ្យអស់មុស្លីមជានិច្ច ទៅរកមាគ៌ាត្រឹមត្រូវនៃការប្រៀនប្រដៅរបស់អល់ឡោះហ៍ عز وجل ។ រាល់ពេលដែលព្រះអង្គ صلوات الله عليه والسلام ធ្វើអន្តរាគមន៍ ដើម្បីដឹកនាំពួកមុស្លីមដែលវង្វេងចេញពីមាគ៌ាត្រឹមត្រូវនោះ វិធីសាស្ត្ររបស់ព្រះអង្គជាគំរូសុក្រឹតនៃការប្រៀនប្រដៅ និងការកែប្រែសីលធម៌ដែលគង់នៅរៀងរហូត ។ ត្រង់នេះយើងសូមលើកឡើងមកបរិយាយនូវការធ្វើអន្តរាគមន៍ខ្លះៗ ដែលបានជិតជាប់ក្នុងជីវិតរស់នៅរបស់អ៊ីម៉ាំអាស្ហុលុល-បៃត៍ عليهم السلام ទាំងអស់ ហើយដែលគេបានឃើញមាននៅក្នុងទំនាក់ទំនងរបស់អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ជាមួយមនុស្សគ្រប់សន្ទាប់ក្នុងសង្គមមុស្លីមយ៉ាងត្រចះត្រចង់ ។

ថ្ងៃមួយអ៊ីម៉ាំបានដើរតាមផ្លូវតូចៗនៃនគរម៉ាឌីណាស្ទ ។ ព្រះអង្គបានដើរកាត់មុខផ្ទះរបស់បុរសម្នាក់ដែលមានឈ្មោះថា ប៊ិស្ហរ៍ បានឮសម្លេងច្រៀងពីក្នុងផ្ទះនោះ ។ មាននារីម្នាក់នៅពីមុខផ្ទះនោះ ព្រះអង្គបានគំនាប់នារីនោះ ហើយបានសួរថាតើអ្នកផ្ទះនេះជាទាសៈឬជាម្ចាស់ ។ នារីរូបនោះភ្ញាក់ផ្អើល បានឆ្លើយភ្លាមថាអ្នកផ្ទះនេះជាម្ចាស់ដែលមានសេរីភាព ។ ព្រះអង្គមានវចនៈថា៖ «អ្នកនិយាយពិត ។ បើអ្នកនោះជាទាសៈ អ្នកនោះប្រាកដជាខ្លាច

ម្ចាស់របស់ខ្លួន ។» លុះនារីនោះត្រឡប់ទៅផ្ទះវិញ ប៊ីស្ហ៍របានសួររក មូលហេតុដែលនាងមកយឺតពេល ។ នារីនេះបានតំណាលអំពីការជួបអ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام និងអំពីការសន្ទនាជាមួយព្រះអង្គ صلوات الله عليه والسلام ។ ប៊ីស្ហ៍រយល់ ន័យមេរៀនដែលអ៊ីម៉ាំដាក់មកឲ្យគាត់ៗក៏បានស្តារលោ បានចោលជីវិតឥត សីលធម៌រហូតមក ។ គាត់រត់តាមអ៊ីម៉ាំដើងទទេ ហូរទឹកភ្នែកសស្រាក់ ដើរ តាមក្រោយព្រះអង្គ صلوات الله عليه والسلام ដើម្បីបង្ហាញមនុស្សទូទៅថាគាត់ស្តារលោកំហុស វិលត្រឡប់មករកអល់ឡោះហ៊ូ عز وجل វិញ ។ ចាប់តាំងពីថ្ងៃនោះមក គេហៅគាត់ ថា ខ្ទីប៊ីស្ហ៍រដើងទទេ (بشر الحافي)ខ្ទី ។ គាត់បានជ្រើសយកជីវិតតាបស ហើយទៅ ជាបុគ្គលល្បីមួយរូបដែលមិនអើពើនឹងទ្រព្យលោកិយ ។

## អ៊ីម៉ាំនិងតបះ (ការកាន់វត្តយ៉ាងតឹងរ៉ឹង)

តបៈឬការកាន់វត្តយ៉ាងតឹងរ៉ឹង (ការប្រព្រឹត្តិយ៉ាងតឹងរ៉ឹង) ជាការនិយម ប្រព្រឹត្តមិនមែនជាទង្វើក្នុងសាសនាទេ ។ ជាឥរិយាបថដែលបុគ្គលជ្រើសយក ពាក់ព័ន្ធនឹងជីវិតនិងទ្រព្យសម្បត្តិ ។ គេអាចគូសរាស់ព្រំដែនរវាងតាបស និងអ្នកគោរពតាមវិន័យសាសនាសាមញ្ញបានដូចតទៅគឺៈ អ្នកគោរពតាម វិន័យចៀសវាងអ្វីដែលច្បាប់ហាម ត្រែកត្រអាលនឹងអ្វីដែលត្រឹមត្រូវស្រប





សម័យស្តេចខ៏លិហ្វហ្វារូន កូនចៅរបស់បារម៉ាក់ អតីតអភិជនជាតិពែរស៍ ត្រូវរាជវាំងសូមផ្សះផ្សាស្តារទំនាក់ទំនងឡើងវិញ ដើម្បីក្លាយទៅជាមន្ត្រីមានអំណាចក្រោយមក ។ ហ្វារូនបន្តធ្វើនយោបាយរបស់ស្តេចមុនដោយពឹងផ្អែកលើពួកបារម៉ាក់ ដើម្បីកម្ចាត់ពួកដែលស្មោះត្រង់ចំពោះអ៊ាលី صلوات الله عليه والسلام ឥតប្រណី ខណៈដែលភ្នាក់ងាររបស់បុគ្គលរូបនេះប្រព្រឹត្តអំពើអយុត្តិធម៌គ្រប់បែបយ៉ាងនិងលួចប្លន់ទ្រព្យសាធារណៈមកធ្វើមាន ។

## ការកាប់សម្លាប់ជាថ្មី

ពាក់កណ្តាលយប់ អារ៉ស្ហ៊ីដបានហៅ ហាមីដ ប៊ិន ក្ហោះហ្ត៏បាស្ង មេបញ្ជាការម្នាក់ដែលស្មោះត្រង់ចំពោះត្រកូលអាប់បាស់ មកជួប ។ ដើម្បីពិសោធឲ្យដឹងថាក្ហោះហ្ត៏បាស្ងស្មោះត្រង់ឬទេនោះ អារ៉ស្ហ៊ីដបានសួរក្ហោះហ្ត៏បាស្ងដូចតទៅគឺ៖

-អ្នកអាចបង្ហាញឲ្យយើងដឹងថាអ្នកស្មោះត្រង់ចំពោះយើងបានដូចម្តេច ?

-ទូលបង្គំព្រមលះបង់ប្រពន្ធកូនដើម្បីព្រះអង្គ ។

-អ្នកអាចបង្ហាញឲ្យយើងដឹងថាអ្នកស្មោះត្រង់ចំពោះយើងបានដូចម្តេច ?

-ទូលបង្គំព្រមលះបង់មប្រពន្ធកូនដើម្បីព្រះអង្គឥតរួញរា ។





ច្បាប់និងការសប្បាយដែលមិនត្រូវហាមឃាត់ ចំណែកឯតាបសឈានហួសកម្រិតបម្រាមស្របច្បាប់ ដើម្បីកាត់ផ្ដាច់ពីអ្វីៗដែលមិនចាំបាច់សម្រាប់ជីវិតរស់នៅ ។ គេទទួលយកអត្ថន័យនេះ តែគេអាចឆ្ងល់អំពីអត្ថន័យច្បាស់លាស់របស់ពាក្យថាតាបសនេះ ។ យើងយល់ឃើញថាពាក្យថា ស៊ូហ្វង់ ច្បាស់លាស់ជាងព្រោះវាមានន័យត្រង់ថា មិនចាប់អារម្មណ៍ទាល់តែសោះ ។ យើងចាំបាច់ត្រូវវែកញែករកភាពខុសគ្នារវាង ស៊ូហ្វង់របស់អ៊ីមុាំអាស្វ៉លុល-បៃត៍ និងតបៈ (ការប្រព្រឹត្តិយ៉ាងតឹងរ៉ឹង) ដែលគេតែងតែប្រើសម្រាប់និយាយអំពីការបង្អត់ខ្លួនឯង ។ និយាយដោយខ្លី ស៊ូហ្វង់ ជាគុណសម្បត្តិដែលអាចមានចំពោះតែមុស្លីមសុក្រឹតនិងសន្ដបុគ្គលទេ ។ ចំណែកឯ តបៈ ជារបៀបរស់នៅតែមួយរបស់សាសនាមួយចំនួន ហើយវិធីរស់នៅបែបនេះមិនបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់លាស់ថា មិនមានអារម្មណ៍ទាល់តែសោះចំពោះជិវិតលោកិយនោះទេ តែជាការខិតខំព្យាយាមកាត់ផ្ដាច់ពីជីវិតលោកិយនេះ ។

ពេលគេនិយាយអំពីតបៈរបស់អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام ត្រូវយល់ឲ្យច្បាស់ថា គេនិយាយអំពីស៊ូហ្វង់របស់ព្រះអង្គ صلوات الله عليه والسلام ដែលមានអត្ថន័យផ្ដោតទៅលើសាសនាអ៊ីស្លាម ។ និយាយឲ្យខ្លី អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មិនយកចិត្តទុក



អ៊ីស្លាម ។ ព្រឹត្តិការណ៍នេះបានកើតឡើងកាលហ៊ូសៃន៍ ប៊ិន អ៊ុាលី កូនចៅរបស់អាល់-ហ៊ាសាន់ صلوات الله عليه والسلام បានបះបោរប្រឆាំងការសង្កត់សង្កិន និងអំណាចផ្ដាច់ការរបស់មូសា អាល់-ហ្វាឌី ។ មូសា អាល់-ហ្វាឌីបានចាត់បញ្ជូនទ័ពធំទៅតទល់ហ៊ូសៃន៍ ប៊ិន អ៊ុាលី ។ ទ័ពនេះបានព័ទ្ធហ៊ូសៃន៍ ប៊ិន អ៊ុាលីនិងបក្សពួកចំនួន ៣០០ នាក់ នៅឯតំបន់មួយដែលហៅថាហ្វាក់ ។ សោកនាដកម្មហ្វាក់ដូចសោកនាដកម្មការបាឡាអ៍បេះបិទ ។ អ្នកបះបោរមួយចំនួនតូចត្រូវគាប់សម្លាប់គ្មានសល់ម្នាក់ ចំណែកឯអ្នកដែលនៅរស់ត្រូវនាំខ្លួនទៅកាន់ស្រុកបាក់ដ្វាដ្វ៍ជាឈ្លើយ ។ នៅទីនោះ ស្ដេចខ៏លិហ្វអាល់-ហ្វាឌីបានបញ្ជាឲ្យប្រហារជីវិតពួកគេទាំងអស់នេះ ។ បុគ្គលសាហាវយង់ឃ្នងរូបនេះបានបែរមករកអ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام បានគំរាមព្រះអង្គ صلوات الله عليه والسلام តែបានស្លាប់មុនបានអនុវត្តតាមគម្រោងការអប្រិយនេះ ។

## សម័យអាររ៉ស៊ីដ

ឆ្នាំ ១៧០ ហ៊ិជ្ជរ៉ោះត្ស័សកាជ ហ្វារូន អាររ៉ស៊ីដឡើងសោយរាជ្យ អ៊ីមុាំអាល់-កាស៊ីម صلوات الله عليه والسلام មានព្រះជន្ម ៤២ វស្សា មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងសំណាក់មុស្លីម ។





ដាក់សោះឡើយនឹងទ្រព្យលោកិយទាំងឡាយគឺៈ ទ្រព្យសម្បត្តិ ស្រី អំណាច និងកេរ្តិ៍ឈ្មោះ ។ ព្រះអង្គ صلوات الله عليه والسلام ស្រឡាញ់តែមួយមុខគត់គឺៈ គោរពសក្ការៈតែអល់ឡោះហ្ عز وجل មួយគត់ ។ យើងសូមលើកឡើងនូវព្រឹត្តិការណ៍ពីរដើម្បីអធិប្បាយបំភ្លឺ “ស៊ុហ្ទដ្ង” ពិសេសរបស់អ៊ីមុាំទីប្រាំពីររបស់យើង ។ ព្រឹត្តិការណ៍ទាំងពីរនេះបញ្ជាក់ឲ្យដឹងថា ព្រះអង្គ صلوات الله عليه والسلام មិនយកចិត្តទុកដាក់នឹងជីវិតលោកិយទេ ។

កាលស្ដេចខ៍លិហ្វអ៊្ហាប់បាស់បានបញ្ជា ឲ្យគេយកអ៊ីមុាំអាល់-កាស៊្ហីម صلوات الله عليه والسلام ទៅឃុំឃាំង ដាក់ខ្នោះដៃជើង នៅក្នុងបន្ទប់ងងឹតក្រោមដី ព្រះអង្គ صلوات الله عليه والسلام មានវចនៈថាៈ «សូមថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ្ عز وجل ដែលបានផ្ដល់ឱកាសឲ្យខ្ញុំបានថ្វាយសេចក្ដីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ចំពោះព្រះអង្គ عز وجل នៅទីបំផុត ។» អស្ចារ្យមែន ទាំងជំនឿ ទាំងសេចក្ដីប្ដេជ្ញាចិត្តត ។ នេះគឺសម្ដីរបស់អរិរុទ្ធបុគ្គលពិតៗ ។ ក្នុងលោកនេះ ព្រះអង្គ صلوات الله عليه والسلام មានតែគោលដៅមួយគត់គឺៈ គោរពសក្ការៈអល់ឡោះហ្ عز وجل តែម្យ៉ាង ។ ក្រៅពីនេះ មិនមានអ្វីគួរឲ្យយកចិត្តទុកដាក់ទេ ។

ស្ដេចខ៍លិហ្វ ហ្វារូន អារ៉ស៊្ហីដ្វ ជាខ៍លិហ្វមានអំណាចលើសស្ដេចខ៍លិហ្វ





ដំណឹងមិនពិត ថាអ៊ីម៉ាំអាល់-កាស៊្ហីម صلوات الله عليه والسلام បម្រុងធ្វើបដិវត្តន៍ ។ មូហាំម៉ាដ់ អាល់-ម៉ាស់ឌីក៏បានចេញបញ្ជាឲ្យគេឃុំឃាំង អ៊ីម៉ាំមូសា អាល់-កាស៊្ហីម صلوات الله عليه والسلام ។ គេក៏បាននាំខ្លួនអ៊ីម៉ាំទៅកាន់ស្រុកបាក់ដាដ់ភ្លាម បានឃុំខ្លួនព្រះអង្គក្នុងបន្ទប់ងងឹត ។

ស្តេចខ៏លិហ្វអ៊ាប់បាស់គិតភ័យយ៉ាងខ្លាំងដោយសារសុបិនមួយ បណ្តាលឲ្យបុគ្គលរូបនេះចេញបញ្ជាឲ្យដោះលែងអ៊ីម៉ាំអាល់-កាស៊្ហីម صلوات الله عليه والسلام ទាំងកណ្តាលយប់អធ្រាត្រ មិនរង់ចាំព្រឹកទេ ។

## ការកាប់សម្លាប់នៅឯហ្វាក់

ស្តេចខ៏លិហ្វមូហាំម៉ាដ់ អាល់-ម៉ាស់ឌីបានសោយរាជ្យ ១០ ឆ្នាំ ។ បន្ទាប់មក មូសា អាល់-ហាឌី កូនរបស់មូហាំម៉ាដ់ អាល់-ម៉ាស់ឌីបានស្នងរាជ្យ ។ ស្តេចខ៏លិហ្វថ្មីកាចសាហាវនិងឃោរឃៅជាងប្អូនរបស់ខ្លួន ។ ដូច្នេះឯងបានជាស្តេចរូបនេះល្បីឈ្មោះជាបុគ្គលកាន់អំណាចផ្តាច់ការ សាហាវឃោរឃៅ ។ មូសា អាល់-ហាឌីធ្វើឲ្យនឹកដល់យ៉ាស៊ីដ មូអាវីយ៉ាស់ ។ បុគ្គលរូបនេះបានប្រព្រឹត្តការកាប់សម្លាប់ដូចបុគ្គលមុនដែរ បានជាប់ឈ្មោះក្នុងក្រាំងចារឈ្មោះបុគ្គលសាហាវយង់ឃ្នងទាំងឡាយដែលគេចាំមិនភ្លេច ក្នុងប្រវត្តិសាស្ត្រ





ត្រកូលអ៊ាប់បាស់ឯទៀត ។ នាសម័យព្រអង្គ صلوات الله عليه والسلام អំណាចពួកអ៊ាប់បាស់បានចូលដល់កម្រិតកំពូល ។ មិនមានអ្វីអាចបៀតបៀន ហារូន អាររ៉ស្ហ៊ីដ បានទេនៅក្នុងលោកនេះ ។ ខ៍លិហ្វរូបនេះទទួលអំណោយពីអធិរាជនានាដែលមានអំណាចជាងគេក្នុងរជ្ជកាលខ្លួន ។ អធិរាជមួយចំនួនបង់ពន្ធឲ្យខ៍លិហ្វរូបនេះរៀងរាល់ឆ្នាំ ជាសញ្ញាបញ្ជាក់ថាខ្លួននៅក្រោមពំនាក់អាស្រ័យរបស់ខ៍លិហ្វរូបនេះ ដូចជាស្តេចនគរមុសគូនិងអធិរាជនៃប្រទេសចិនជាដើម ។

ទោះជាមានអំណាចប៉ុណ្ណេះក៏ដោយ ហារូនមិនអាចត្រេកត្រអាលនឹងជីវិតខ្លួនបានទេ ព្រោះតែដឹងច្បាស់ថាខ្លួនគ្រាន់តែជាបុគ្គលប្លន់យកអំណាចគេមកធ្វើជាអំណាចឯង ប្រមុខស្របច្បាប់របស់សហគមន៍មុស្លីមមិនមែនអ្នកណាក្រៅពី អ៊ីម៉ាំ មូសា អាល់-កាស៊្ទឹម صلوات الله عليه والسلام នោះទេ ។ តែអ៊ីម៉ាំអាល់-កាស៊្ទឹម صلوات الله عليه والسلام មិនដែលប្រហែសខ្លួនដល់ថ្នាក់ផ្តល់ឱកាសល្អឲ្យ ហារូន អាររ៉ស្ហ៊ីដ ទេ ហើយបុគ្គលរូបនេះបានញញើតញញើមអស់រយៈពេលដ៏យូរ មុននឹងបញ្ជាឲ្យគេដាក់ថ្នាំបំពុលព្រះអង្គ ។

នៅទីបំផុត ព្រោះតែច្រណែនឈ្នានីសនិងគុំកួនទៅលើបុគ្គលបរិសុទ្ធនិងរីករាយជាងគេក្នុងសម័យនោះ ទើបបុគ្គលរូបនេះបញ្ជាឲ្យចាប់ខ្លួនព្រះអង្គទៅ

ដាក់ពន្ធនាគារ ។ លុះបានដឹងថាអ្នកទោសបានធ្វើឲ្យបន្ទប់ឃុំឃាំងរបស់ខ្លួនទៅជាកន្លែងធ្វើសក្ការៈអល់ឡោះហ៊ូ عز وجل បុគ្គលនេះបានសម្រេចចិត្តល្បងពិសោធអាវុធទាក់ទាញចិត្ត ។ ហារូន អារ៉ស្ហ៊ីដ បានបញ្ជាឲ្យចាត់បញ្ជូននារីដែលមានរូបឆោមស្អាត គួរបេតី ទៅរកអ៊ីម៉ាំក្នុងបន្ទប់ឃុំឃាំងព្រះអង្គ ដោយគិតនារីរូបនេះនឹងអាចធ្វើឲ្យអ៊ីម៉ាំលំអៀងចេញពីការគោរពសក្ការៈអល់ឡោះហ៊ូ عز وجل ។ ហារូន អារ៉ស្ហ៊ីដ បានដាក់បញ្ជាឲ្យឆ្មាំពីរនាក់ឃ្លាំមើលបន្ទប់ឃុំឃាំងអ៊ីម៉ាំ ហើយឲ្យធ្វើសេចក្ដីរាយការណ៍ប្រាប់ខ្លួនអំពីព្រឹត្តិការណ៍ដែលនឹងឡើងនៅទីនេះ ។ មិនយូរប៉ុន្មានឆ្មាំទាំងពីរនាក់ក៏បានមកធ្វើរបាយការណ៍ប្រាប់ម្ចាស់ខ្លួននូវរឿងរ៉ាវមួយ ដែលធ្វើឲ្យបុគ្គលរូបនេះរំខានចិត្តជាទីបំផុតគឺ៖ អ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام មិនត្រឹមតែមិនឈប់ធ្វើសក្ការបូជាអល់ឡោះហ៊ូ عز وجل ទេ នារីរូបស្អាតបែរជាតាមព្រះអង្គទៀតផង ដោយធ្វើសក្ការៈបូជាអល់ឡោះហ៊ូ عز وجل តាមក្រោយអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام យ៉ាងស៊ប់ចិត្ត ។

នៅក្នុងលោកនេះ មិនមានអ្វីអាចធ្វើឲ្យអវិរុទ្ធបុគ្គលលំអៀងពីការគោរពបូជាអល់ឡោះហ៊ូ عز وجل បានទេ ។ នេះគឺអត្ថន័យរបស់ ស៊ុហ្ទដ់ គឺការមិនអើពើដាច់ខាតនឹងសម្បត្តិលោកិយ ។



# ឯបាកុំដ្ងាដ់

ស្ដេចខ៊ិលិហ្វត្រកូលអាប់បាស់ ឈ្មោះអាល់-ម៉ានស៊្ហូរបានចាកលោកឆ្នាំ ១៥៨ ហ៊ិជ្ជ៉រ៉ោះត្ត៍សករាជ បានចោលអំណាចឲ្យទៅកូនប្រុសឈ្មោះមូហ្ហាំម៉ាដ់ អាល់-ម៉ាស់ឌ្ហីដែលបានសោយរាជ្យលើចក្រភពដ៏ធំល្វឹងល្វើយ ដ៏សម្បូរឥទ្ធិពល ។ អាស្រ័យហេតុនេះ ស្ដេចខ៊ិលិហ្វរូបនេះអាចប្រើនយោបាយប្រមូលយកអ្នកប្រឆាំងទាំងអស់មកវិញ លើកលែងតែអាស់ហុល-បៃត៍ عليهم السلام ។ ដូច្នេះពន្ធនាគារទាំងអស់បានដោះលែងអ្នកទោសនយោបាយ ប្រាក់មួយចំនួនធំត្រូវបានចំណាយ ដើម្បីទិញសេចក្ដីស្មោះត្រង់របស់បុគ្គលណាដែលមានអំណាចឬមានការគាំទ្រពីមហាជន ដូចជាចៅក្រម អ្នកប្រាជ្ញ មេកុលសម្ព័ន្ធ ហោរ គ្រូបោកប្រាស់ និងអ្នកនិទានរឿងព្រេងឲ្យគេស្ដាប់ ។ សកម្មភាពកាឡៃហ្ចាឌីស្ហបានកើតមានឡើង និងបានរីកចម្រើនឡើង ផ្ដល់គុណប្រយោជន៍ដល់ពួកអ៊ាប់បាស់ ។ ប្រវត្តិសាស្ត្របានឲ្យដឹងថាអ្នកឱកាសនិយមមួយចំនួនបានក្បត់ អ៊ាលី ប៊ិន អាប៊ូ ត្ត៏លិប صلوات الله عليه والسلام ដោយលក់ហ្ចាឌីស្ហក្លែងក្លាយឲ្យពួកអ៊ាប់បាស់ ។ ធម្មតា មិនមានហេតុផលដើម្បីឃុំឃាំងខ្លួនអ៊ីម៉ាំអាល់-កាស៊ីម صلوات الله عليه والسلام ទេ តែស្ដេចខ៊ិលិហ្វអ៊ាប់បាស់ត្រចៀកស្រាលស្ដាប់ពួកឱកាសនិយម ដែលព្យាយាមខិតចូលមកជិតខ្លួនដោយនាំមកនូវ